# សុន្ទរកថា
# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបិទសិក្ខាសាលាស្តីពី "ការប្រឆាំងការសម្អាតប្រាក់"
## ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅធនាគារជាតិនៃកម្ពុជា

******

សូមគោរព

- **លោក Jean Pierre MICHAU ទីប្រឹក្សាទេសាភិបាលធនាគារកណ្តាលបារាំង**
- **លោក លោកស្រី និងអ្នកនាងកញ្ញា ជាសិក្ខាកាមទាំងអស់ ជាទីមេត្រី !**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានមកជួបជុំជាមួយ អស់លោក លោកស្រី និងនាងកញ្ញាជាសិក្ខាកាមទាំងអស់ជាថ្មីម្តងទៀត ក្នុងឱកាសប្រារព្ធពិធីបិទសិក្ខាសាលាស្តីពី "ការប្រឆាំងការសម្អាតប្រាក់" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ៣ ដល់ ៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

បន្ទាប់ពីបានចូលរួមស្តាប់បទឧទ្ទេសនាមក្នុងរយៈពេល ២ថ្ងៃកន្លងមកនេះ ខ្ញុំជឿជាក់ថា អស់លោក លោកស្រី និងនាងកញ្ញាជាសិក្ខាកាមទាំងអស់បានទទួលចំណេះដឹងថ្មីៗ បន្ថែមទៀតអំពីរបៀបនៃការសម្អាតប្រាក់ ក៏ដូចជាវិធីសាស្ត្រប្រឆាំងការសម្អាតប្រាក់ផងដែរ ។ ដូចដែលយើងបាន ដឹងស្រាប់ហើយថា ការសម្អាតប្រាក់មានផលប៉ះពាល់យ៉ាងធំធេងចំពោះសង្គម និងសេដ្ឋកិច្ច ហើយជាពិសេសទៅទៀត ចំពោះប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ដែលជាប្រព័ន្ធដ៏សំខាន់មួយនៃសេដ្ឋកិច្ច ហើយទោះជាយើងមិនបានដឹងអំពីទំហំ ឬតួលេខនៃការសម្អាតប្រាក់តាមប្រព័ន្ធនេះច្បាស់លាស់ក៏ដោយ ក៏ការសម្អាតប្រាក់ធ្វើឱ្យអន្តរាយដល់មុខងារ និងសុចរិតភាព របស់ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុទាំងមូល និងជាពិសេសធ្វើឱ្យបាត់បង់ជំនឿចិត្តពីអតិថិជន ដែលជាចំណុចស្នូលមួយ ដែលពិបាកនឹងស្តារឱ្យប្រសើរឡើងវិញបាន ។ ការរក្សាជំនឿទុកចិត្តពីសាធារណៈជនគឺទាមទារពេលវេលាមួយយូរអង្វែងមិនអាចកំណត់បាន ប៉ុន្តែដើម្បីធ្វើឱ្យការងារនេះឱ្យបានរលូនគឺត្រូវចាប់ផ្តើមតាមវិធីសាស្ត្រពង្រឹងការទុកចិត្តជាបណ្តើរៗ ដោយត្រូវធ្វើយ៉ាងណាការពារកុំឱ្យប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុត្រូវបានរំលោភបំពានពីសំណាក់អ្នកសម្អាតប្រាក់ ។ ដើម្បី អនុវត្តឱ្យទទួលបាននូវលទ្ធផលជាវិជ្ជមាន និងប្រកបប្រសិទ្ធភាព បុគ្គលរាយការណ៍ត្រូវបំពេញតួនាទីរបស់ខ្លួនជាអ្នករាយការណ៍ឱ្យបានខ្ជាប់ខ្ជួនដោយឈរលើទស្សនៈប្រុងប្រយ័ត្នគ្រប់ជំហាន ។

**លោក លោកស្រី និងនាងកញ្ញា ជាសិក្ខាកាមទាំងអស់ ជាទីមេត្រី !**

ទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅម្តងទៀតចំពោះធនាគារកណ្តាលនៃប្រទេសបារាំងដែលតែងតែបន្តការគាំទ្រដល់ធនាគារជាតិនៃកម្ពុជា និងសូមថ្លែងអំណរគុណលោក Jean Pierre MICHAU ដែលបានចំណាយពេលធ្វើបទឧទ្ទេសនាម និងផ្តល់បទពិសោធន៍ល្អៗសម្រាប់អង្គសិក្ខាសាលាក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ ហើយខ្ញុំសង្ឃឹមថា យើងនឹងបន្តកិច្ចសហប្រតិបត្តិការគ្នាយ៉ាងរឹងមាំទៅថ្ងៃអនាគតខាងមុខទៀត ។

ខ្ញុំសូមជូនពរលោក Jean Pierre MICHAU និងលោកស្រី ក្នុងដំណើរកំសាន្តទៅខេត្តសៀមរាប ដើម្បីធ្វើទស្សនកិច្ចប្រាសាទអង្គរវត្ត និងប្រាសាទបុរាណដែលជាស្នាដៃដ៏ល្អគ្មានពីររបស់បុព្វបុរសខ្មែរ និងសូមឱ្យដំណើរត្រឡប់ទៅប្រទេសបារាំងវិញប្រកបដោយសុវត្ថិភាព ហើយក៏សូមជូនពរដល់អស់លោក លោកស្រី និងនាងកញ្ញាជាសិក្ខាកាមទាំងអស់ ជាពិសេសក្នុងទិវាបុណ្យជាតិថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០០៨ នេះ សូមឱ្យទទួលបាននូវសុខភាពល្អ បរិបូណ៌ និងជោគជ័យគ្រប់ភារកិច្ច ។

ខ្ញុំសូមប្រកាសបិទកម្មវិធីសិក្ខាសាលាស្តីពី “ការសម្អាតប្រាក់” ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**